**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈរដ្ឋមន្ត្រី**

ក្រសួងបរិស្ថាន

លេខៈ ៣៦៦ [illegible] ប.ស្ថ

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០០៧

# សា រា ច រ

## ស្តីពី

### ការណែនាំអនុវត្តការហាមជក់បារី នៅកន្លែងធ្វើការ សាលប្រជុំ

យោងអនុសញ្ញារបស់អង្គការសុខភាពពិភពលោកស្តីពីការត្រួតពិនិត្យថ្នាំជក់

យោងតាមខ្លឹមសារនៃលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ១២៧០ សជណ-អវ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីគោលការណ៍ហាមជក់បារីនៅតាមកន្លែងធ្វើការ របស់មន្ត្រីរាជការ សាលប្រជុំ រោងមហោស្រពនានា ។

យោងតាមស្មារតីអង្គសិក្ខាសាលាថ្ងៃទី ១៤-១៧-១៨ និងថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ២០០៧ ដែលបានបង្ហាញឱ្យឃើញថា ការជក់បារីអាចបណ្តាលឱ្យកើត ជំងឺមហារីកសួត ដាច់សសៃឈាមខួរក្បាល មហារីកមាត់ តាំងបេះដូង គ្រិនសរសៃឈាម មហារីកក្រពះ ពោកនោម របស់អ្នកជក់ និងអ្នកនៅជុំវិញ ហើយចំពោះស្ត្រីដែលមានគភ៌ ផ្សែងបារីអាចធ្វើឱ្យទារកដែលកើតមកខ្វះទម្ងន់ និងមានរាងកាយមិនគ្រប់លក្ខណៈ ។ ជារួមផលវិបាកនៃការជក់ និងការស្រូបផ្សែងបារីពីអ្នកជក់ បានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សុខភាព បរិស្ថាន ធ្វើឱ្យខាតបង់ថវិកាគ្រួសារ និងសេដ្ឋកិច្ចជាតិ ។

ដើម្បីអនុវត្ត នូវគោលនយោបាយ កាត់បន្ថយភាពក្រីក្រ របស់រាជរដ្ឋាភិបាល និងជាពិសេសដើម្បីលើកកំពស់សុខភាពជូនមន្ត្រីរាជការ ក្រសួងបរិស្ថានដោយផ្តើមចេញពីការលះបង់ទំលាប់ជក់បារីនោះ ក្រសួងបរិស្ថានសូមធ្វើការណែនាំអំពីការអនុវត្តន៏ការហាមជក់បារី ដូចតទៅ :

១-ហាមជក់បារីនៅក្នុងបន្ទប់ធ្វើការ សាលប្រជុំ បន្ទប់អាគារស្នាក់នៅមន្ត្រីបរិស្ថានុរក្ស បន្ទប់ទឹក និងតាមផ្លូវដើរចេញចូលកន្លែងធ្វើការ ។

២-ស្នើចូលរួមធ្វើការអប់រំស្តីពីផលប៉ះពាល់សុខភាពដោយសារការប្រើប្រាស់ថ្នាំជក់ដើម្បីទប់ស្កាត់ឬកាត់បន្ថយការជក់ រហូតឈានដល់ការលះបង់ទម្លាប់ជក់បារីទាំងស្រុង ។

ទន្ទឹមនឹងនេះ បើអង្គភាព នៅថ្នាក់កណ្តាល និងមន្ទីរបរិស្ថាន ស្នាក់ការតំបន់ការពារធម្មជាតិ ខេត្ត-ក្រុងក្រោមឱវាទក្រសួងបរិស្ថានយល់ឃើញថា មិនទាន់អាចបំបាត់ការជក់បារីទាំងស្រុងទេ ស្នើសុំឱ្យមានកន្លែងមួយដាច់ដោយឡែកទុកសំរាប់អ្នកញៀនបារីជក់នៅទីនោះ ជៀសវាងប៉ះពាល់ដល់សុខភាពអ្នកដទៃដែលមិនជក់ ។ ព្រមជាមួយនេះត្រូវរៀបចំបិទរូបភាពផ្សព្វផ្សាយអប់រំសុខភាព ស្តីពីផលប៉ះពាល់ដល់សុខភាពដោយសារការជក់បារី ។

៣-ក្នុងករណីមានការល្មើសពីសេចក្ដីណែនាំដែលបានរៀបរាប់ខាងលើ ត្រូវទទួលការណែនាំ ។

គ្រប់អង្គភាព នៅថ្នាក់កណ្ដាល និងមន្ទីរបរិស្ថាន ស្នាក់ការតំបន់ការពារធម្មជាតិ ខេត្ត-ក្រុង ក្រោមឱវាទក្រសួងបរិស្ថានមានភារកិច្ចអនុវត្តសារាចរណែនាំនេះឱ្យបានលទ្ធផលល្អប្រសើរ ។៚

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

មុក_ម៉ារ៉េត

បណ្ឌិត.គីមីវិទ្យា

**<u>ចម្លងជូន</u> :**

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-ក្រសួងពាក់ព័ន្ធ

-អង្គការក្រៅរដ្ឋាភិបាល

" ដើម្បីជូនជាព័ត៌មាន "

-គ្រប់អង្គភាពនៅថ្នាក់កណ្ដាល

-មន្ទីរបរិស្ថាន ខេត្ត-ក្រុង

-ស្នាក់ការតំបន់ការពារធម្មជាតិ ខេត្ត-ក្រុង

" ដើម្បីអនុវត្ត "

-ឯកសារ-កាលប្បវត្តិ